Washington State Department of HEALTH

SEPTEMBER 2024



# ទទួលបានការចាក់វ៉ាក់សាំង ដើម្បីការពារប្រឆាំងនឹងជំងឺ COVID-19

**វ៉ាក់សាំងជំងឺ COVID-19 ឆ្នាំ 2024-2025 ថ្មីមានសុវត្ថិភាព ប្រសិទ្ធភាព និងត្រូវបានណែនាំឱ្យប្រើសម្រាប់អ្នកគ្រប់គ្នាដែលមានអាយុ 6 ខែឡើងទៅ។**

មនុស្សភាគច្រើនដែលមានអាយុ 5 ឆ្នាំឡើងទៅគ្រាន់តែចាក់ដូសឆ្នាំ 2024-2025 ថ្មីមួយដូស ដើម្បីឱ្យទាន់សភាពការណ៍ជាការស្រេច។

- កុមារដែលមានអាយុ 6 ខែដល់ 4 ឆ្នាំអាចនឹងត្រូវចាក់លើសពីមួយដូសនៃវ៉ាក់សាំងជំងឺ COVID-19 ប្រភេទ mRNA ឆ្នាំ 2024-2025 ថ្មី ដើម្បីឱ្យទាន់សភាពការណ៍ជាមួយនឹងការចាក់វ៉ាក់សាំងជំងឺ COVID-19។
- មនុស្សអាយុ 6 ខែឡើងទៅដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយពីកម្រិតមធ្យមទៅធ្ងន់ធ្ងរគួរតែចាក់ស៊េរីចម្បងនៃវ៉ាក់សាំងជំងឺ COVID-19 ឆ្នាំ 2024-2025 ស្របតាមអាយុឱ្យគ្រប់ចំនួន និងអាចចាក់ដូសបន្ថែមនៃវ៉ាក់សាំងជំងឺ COVID-19 ឆ្នាំ 2024-2025 ថ្មី ក្រោយចាក់ដូសចុងក្រោយយ៉ាងតិច 2 ខែ។

## តើវ៉ាក់សាំង COVID-19 ណាខ្លះដែលមានផ្តល់ជូននាពេលបច្ចុប្បន្ន?

### Pfizer-BioNTech/Comirnaty

បញ្ជីឱសថឆ្នាំ 2024-2025 សម្រាប់អ្នកមានអាយុ 6 ខែឡើងទៅ*

### Moderna/Spikevax

បញ្ជីឱសថឆ្នាំ 2024-2025 សម្រាប់អ្នកមានអាយុ 6 ខែឡើងទៅ*

### Novavax

រូបមន្តឆ្នាំ 2024-2025 សម្រាប់អាយុ 12 ឆ្នាំឡើងទៅ

**Comirnaty និង Spikevax គឺជាឈ្មោះម៉ាករបស់ វ៉ាក់សាំង mRNA ដែលបច្ចុប្បន្នត្រូវបានអនុញ្ញាតសម្រាប់អ្នកមានអាយុ 12 ឆ្នាំឡើងទៅ។ វ៉ាក់សាំង Pfizer និង Moderna mRNA ត្រូវបានអនុញ្ញាតសម្រាប់អ្នកមានអាយុ 6 ខែ ឡើងទៅ។*

## តើមានសុវត្ថិភាពដែរទេ ប្រសិនបើចាក់វ៉ាក់សាំងផ្សេងទៀតស្របពេលចាក់វ៉ាក់សាំង COVID-19?

បាទ/ចាស គឺមានសុវត្ថិភាពបើអ្នកចាក់វ៉ាក់សាំង COVID-19 ស្របពេលដែលអ្នកទទួលបានវ៉ាក់សាំងផ្សេងទៀត។ អ្នកមិនចាំបាច់កំណត់ពេលចាក់វ៉ាក់សាំងដែលមានការណែនាំផ្សេងទៀតដាច់ដោយឡែកពីការចាក់វ៉ាក់សាំង COVID-19 នោះទេ។ ការណាត់ជួបចាក់វ៉ាក់សាំង COVID-19 គឺជាឱកាសមួយផ្សេងទៀតដើម្បីតាមដានវ៉ាក់សាំងដែលបានណែនាំទាំងអស់។

## តើកូនរបស់ខ្ញុំត្រូវការចំនួនប៉ុន្មានដូសដើម្បីបន្តបច្ចុប្បន្នភាព?

យើងណែនាំឱ្យកុមារដែលមិនបានចាក់វ៉ាក់សាំងចាប់ពីអាយុ 6 ខែដល់អាយុ 4 ឆ្នាំទៅទទួលវ៉ាក់សាំង COVID-19 Moderna ឆ្នាំ 2024-2025 ដែលបានធ្វើបច្ចុប្បន្នភាពចំនួន 2 ដូស ឬ 3 ដូសនៃវ៉ាក់សាំង COVID-19 Pfizer ឆ្នាំ 2024-2025 ដែលបានធ្វើបច្ចុប្បន្នភាព។

យើងណែនាំឱ្យកុមារមានអាយុ 6 ខែ - 4 ឆ្នាំដែលបានចាក់វ៉ាក់សាំងពីមុនទៅទទួលវ៉ាក់សាំង COVID-19 Moderna ឬ Pfizer ឆ្នាំ 2024-2025 ដែលបានធ្វើបច្ចុប្បន្នភាព 1 ឬ 2 ដូស (ពេលវេលា និងចំនួនដូសក្នុងការគ្រប់គ្រងអាស្រ័យលើវ៉ាក់សាំង COVID-19 ពីមុនដែលបានទទួល)។

កុមារដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅនឹងបន្តបច្ចុប្បន្នភាពជាមួយការចាក់វ៉ាក់សាំង COVID-19 ប្រសិនបើពួកគេទទួលបានយ៉ាងហោចណាស់ 1 ដូសនៃវ៉ាក់សាំង COVID-19 Moderna ឬ Pfizer ឆ្នាំ 2024-2025 ដែលបានធ្វើបច្ចុប្បន្នភាព។

បុគ្គលអាយុ 12 ឆ្នាំឡើងទៅដែលមិនបានចាក់វ៉ាក់សាំងអាចចាក់ 2 ដូសនៃវ៉ាក់សាំងជំងឺ COVID-19 ស៊េរី Novavax ឆ្នាំ 2024-2025 ដើម្បីបង្កើនប្រសិទ្ធភាពដោយចាក់មុនក្រោយគ្នា 3 សប្តាហ៍។

បុគ្គលអាយុ 12 ឆ្នាំឡើងទៅដែលធ្លាប់ចាក់វ៉ាក់សាំងជំងឺ COVID-19 (និងមិនទាន់ចាក់វ៉ាក់សាំងជំងឺ COVID -19 ស៊េរី mRNA ឆ្នាំ 2024-2025) អាចចាក់ 1 ដូសនៃវ៉ាក់សាំងជំងឺ COVID-19 ស៊េរី Novavax ឆ្នាំ 2024-2025 ដើម្បីបង្កើនប្រសិទ្ធភាព។

កុមារដែលមានអាយុចាប់ពី 6 ខែឡើងទៅដែលភាពស៊ាំត្រូវគំរាមកំហែងពីកម្រិតមធ្យម ឬធ្ងន់ធ្ងរគួរតែចាក់ឱ្យគ្រប់ស៊េរី 3 ដូស និងអាចទទួលបានមួយដូសបន្ថែម ឬច្រើនជាងនេះនៃវ៉ាក់សាំង
COVID-19 ឆ្នាំ 2024-2025 ដែលបានធ្វើបច្ចុប្បន្នភាព យ៉ាងហោចណាស់ 2 ខែបន្ទាប់ពីកម្រិតចុងក្រោយរបស់ពួកគេ។

## តើមានការចំណាយសម្រាប់វ៉ាក់សាំងជំងឺ COVID-19 ដែរទេ?

ដូចវ៉ាក់សាំងផ្សេងទៀតដែរ វ៉ាក់សាំងជំងឺ COVID-19 ត្រូវបានរ៉ាប់រងដោយគម្រោងធានារ៉ាប់រងភាគច្រើន។ វ៉ាក់សាំងជំងឺ COVID-19 នឹងបន្តមានផ្តល់ជូនដោយឥតគិតថ្លៃសម្រាប់កុមារគ្រប់រូបក្នុងរដ្ឋវ៉ាស៊ីនតោនរហូតដល់ពួកគេមានអាយុ 19 ឆ្នាំតាមរយៈ Childhood Vaccine Program (កម្មវិធីវ៉ាក់សាំងសម្រាប់កុមារ) (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។ កម្មវិធីសម្រាប់មនុស្សពេញវ័យក៏មានផងដែរ ដែលអាចជួយរ៉ាប់រងថ្លៃចាក់វ៉ាក់សាំង ប្រសិនបើពួកគេមិនមានធានារ៉ាប់រងសុខភាព ឬគម្រោងរបស់ពួកគេមិនរ៉ាប់រងលើវ៉ាក់សាំងនេះ។ ប្រសិនបើអ្នកជាមនុស្សពេញវ័យអាយុ 19 ឆ្នាំដែលមិនត្រូវបានធានារ៉ាប់រង ឬធានារ៉ាប់រងមិនគ្រប់គ្រាន់ អ្នកមានសិទ្ធិចាក់វ៉ាក់សាំងជំងឺ COVID-19 ឆ្នាំ 2024-2025 ក្នុងតម្លៃទាបតាមរយៈអ្នកផ្តល់សេវាដែលចូលរួមក្នុង Washington State Adult Vaccine Program (AVP, កម្មវិធីវ៉ាក់សាំងមនុស្សពេញវ័យនៃរដ្ឋវ៉ាស៊ីនតោន) (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។ អ្នកផ្តល់សេវានៃកម្មវិធី AVP របស់អ្នកអាចគិតថ្លៃរដ្ឋបាលក្នុងការចាក់វ៉ាក់សាំង ប៉ុន្តែអ្នកអាចស្នើឱ្យលើកលែងថ្លៃសេវានេះបាន ប្រសិនបើអ្នកគ្មានលទ្ធភាពបង់ប្រាក់ទេ។ អ្នកផ្តល់សេវានៃកម្មវិធី AVP មិនអាចបដិសេធមិនចាក់វ៉ាក់សាំងជំងឺ COVID-19 ឱ្យអ្នកទេ ប្រសិនបើអ្នកគ្មានលទ្ធភាពបង់។ អ្នកអាចស្វែងរកអ្នកផ្តល់សេវាដែលចូលរួមដោយប្រើផែនទីអ្នកផ្តល់សេវានៃកម្មវិធី AVP (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។ អ្នកអាចហៅទូរសព្ទទៅអ្នកផ្តល់សេវានៃកម្មវិធី AVP ដែលនៅជិតអ្នក ដើម្បីសួរព័ត៌មានបន្ថែមអំពីផលិតផលដែលមានផ្តល់ជូន និងកំណត់ពេល។

**ទំនាក់ទំនង**
Covid.Vaccine@doh.wa.gov
360-236-3642

ការណែនាំដល់អ្នកជំងឺសម្រាប់ការចាក់វ៉ាក់សាំង COVID-19 - https://www.cdc.gov/vaccines/covid-19/clinical-considerations/interim-considerations-us.html#covid-vaccines

Childhood Vaccine Program - https://doh.wa.gov/public-health-healthcare-providers/public-health-system-resources-and-services/immunization/childhood-vaccine-program

Adult Vaccine Program - https://doh.wa.gov/public-health-healthcare-providers/public-health-system-resources-and-services/immunization/adult-vaccine-program

Vaccines.gov - https://www.vaccines.gov/

DOH 820-246 Khmer
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 1-800-525-0127។ អតិថិជនដែលស្តាប់មិនឮ ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ doh.information@doh.wa.gov។